**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៧៩ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មចំណុះអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញាឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៨ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហគមន៍កសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើរដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការ

កៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មចំណុះអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អង្គការលេខថ្មីរបស់អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម មានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ កសាងផែនការ និងគម្រោងកម្មវិធីអភិវឌ្ឍន៍សម្រាប់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា និងកសិដ្ឋានផលិតកម្មកសិកម្ម ក្នុងទិសដៅបង្កើនផលិតភាពនិងផលិតកម្មកសិកម្ម បង្កើនប្រសិទ្ធភាពនៃការបញ្ចូលបច្ចេកទេសកសិកម្ម និងបង្កើនឥទ្ធិពលចចារទីផ្សារ
- បង្កើតកម្មវិធីផ្សព្វផ្សាយ អប់រំ និងលើកកម្ពស់ការយល់ដឹងអំពីការអភិវឌ្ឍន៍សហគមន៍កសិកម្មសហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- សម្របសម្រួលរវាងសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាជាមួយផ្នែកឯកជនឬផ្នែកពាក់ព័ន្ធផ្សេងទៀត
- សម្របសម្រួលជាមួយក្រសួងស្ថាប័នរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ លើការងារអភិវឌ្ឍន៍សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ធ្វើបច្ចុប្បន្នភាពទិន្នន័យសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា និងរៀបចំរបាយការណ៍វឌ្ឍនភាពស្តីពីការងារអភិវឌ្ឍន៍សហគមន៍កសិកម្ម ជូនអគ្គនាយកដ្ឋានកសិកម្ម
- សម្របសម្រួលក្នុងការបង្កើតសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ក្នុងការចុះបញ្ជីទទួលស្គាល់នីត្យានុកូលភាព
- សិក្សា និងវាយតម្លៃពីស្ថានភាពសេដ្ឋកិច្ចរបស់ហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ ព្រមទាំងផ្តល់ព័ត៌មានទីផ្សារកសិផលដល់សហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្ម

- ចូលរួមតាមដាន និងវាយតម្លៃការប្រព្រឹត្តទៅនិងប្រតិបត្តិការ របស់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ចូលរួមសិក្សា វាយតម្លៃ និងសម្របសម្រួលដោះស្រាយបណ្តឹងតវ៉ា និងវិវាទរបស់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់ភ្នាក់ងារអភិវឌ្ឍន៍សហគមន៍កសិកម្ម
- អប់រំ កសាង និងពង្រឹងសមត្ថភាពរបស់ថ្នាក់ដឹកនាំនិងសមាជិកសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា លើការងារអភិវឌ្ឍន៍សហគមន៍កសិកម្ម
- សម្របសម្រួលរៀបចំសន្និបាតសហគមន៍កសិកម្មថ្នាក់ជាតិប្រចាំឆ្នាំ
- សម្របសម្រួលនិងគាំទ្របច្ចេកទេសកសិកម្មសមស្របដល់សហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្ម
- ជំរុញការងារអភិវឌ្ឍន៍មុខជំនួញរបស់សហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្ម ណែនាំរបៀបរបបចុះបញ្ជីគណនេយ្យដល់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា លើការងារសវនកម្មផ្ទៃក្នុង
- រៀបចំកម្មវត្ថុសវនកម្មផ្ទៃក្រៅសម្រាប់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- អនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកសិកម្មប្រគល់ជូន។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ដឹកនាំដោយប្រធានមួយ(១)រូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា៣.-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៤.-**

ក្រៅពីចំណុចត្រទី១នៃមាត្រា៣៥ ខ្លឹមសារអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរក្សាជាធរមានដដែល។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ១សភា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ..១៧៤..អនក្រ.បក ចុះថ្ងៃទី...១៤...ខែឧសភា.ឆ្នាំ២០១៤

## អង្គការលេខរបស់អគ្គនាយកដ្ឋានកសិកម្ម

**ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកសិកម្ម**

- នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យនិងសហប្រតិបត្តិការអន្តរជាតិ
- នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ
- នាយកដ្ឋាន គ្រប់គ្រងធនធានដីកសិកម្ម
- នាយកដ្ឋាន អភិវឌ្ឍន៍សហគមន៍កសិកម្ម
- នាយកដ្ឋានដំណាំស្រូវ
- នាយកដ្ឋានគ្រឿងយន្តកសិកម្ម
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
- នាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំ
- នាយកដ្ឋានដំណាំឧស្សាហកម្ម
- មន្ទីរពិសោធន៍ជាតិកសិកម្ម